DEICHMANN

# ក្រមសីលធម៌

DEICHMANN

ក្រមសីលធម៌ DEICHMANN នេះត្រូវបានដាក់បញ្ចូលក្រមសីលធម៌
នៃគំនិតផ្តួចផ្តើមការអនុលោមសង្គមក្នុងមុខពាណិជ្ជកម្ម (BSCI)
ជា កំណែប្រែខែមករាឆ្នាំ2014។ ក្រុមហ៊ុន DEICHMANN
បានទទួលស្គាល់ក្រមសីលធម៌ BSCI និងបានកែសម្រួលទៅតាមគ្រោង
ការណ៍របស់ខ្លួនដើម្បីចូលរួមកាន់តែប្រសើរទៅក្នុងឥទ្ធិពលរបស់ BSCI។

# បុព្វកថា

យើងជា ក្រុមហ៊ុន DEICHMANN យល់ឃើញថា យើង មានកាតព្វកិច្ចក្នុងការបន្តនូវភាពទទួលខុសត្រូវ ចំពោះឥទ្ធិពលសង្គម និងបរិស្ថាននៃប្រតិបត្តិការជាសកលរបស់យើង។ ដើម្បីធ្វើឲ្យគោលជំហររបស់យើង ច្បាស់លាស់សម្រាប់ដៃគូពាណិជ្ជកម្ម និងក្រុមហ៊ុន ចូលរួមទាំងអស់នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និយោជិត និងភាគីពាក់ព័ន្ធរបស់យើងទាំងអស់ យើងបានរៀបចំ ក្រមសីលធម៌ DEICHMANN នេះឡើង (កំណែប្រែឆ្នាំ 2016)។ ជាតម្រូវការដាច់ ខាតរបស់យើងដែលគ្រប់ ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងក្រុមហ៊ុន ចូលរួមនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ទាំងអស់ ដោយពុំ មានករណីលើកលែង ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌នេះ។

ក្រមសីលធម៌ DEICHMANN នេះយកលំនាំតាម គោលការណ៍ របស់គំនិតផ្តួចផ្តើមការអនុលោមសង្គម ក្នុងមុខពាណិជ្ជកម្ម (BSCI) និងគាំទ្រតាមរយៈកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ ដូចជាសេចក្តីប្រកាសជា សកលស្តីពីសិទ្ធិមនុស្ស, គោលការណ៍ណែនាំសម្រាប់ សិទ្ធិកុមារ និងសកម្មភាពអាជីវកម្ម, គោលការណ៍ណែនាំ ដោយអង្គការសហប្រជាជាតិ "អាជីវកម្ម និងសិទ្ធិ មនុស្ស", គោលការណ៍ OECD ព្រមទាំងកិច្ចព្រមព្រៀង ជាសកលនៃអង្គការសហប្រជាជាតិ អនុសញ្ញា និង អនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ (ILO) ដែល មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងការ  លើកកម្ពស់ លក្ខខណ្ឌការងារក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។

ជាមួយក្រមសីលធម៌ DEICHMANN យើងធ្វើតាម គោលបំណងដើម្បីណែនាំ និងអភិវឌ្ឍគោលការណ៍ របស់យើងរួមគ្នាជាមួយដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងភាគីទាំងអស់ ដែលពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ នៅក្នុងករណីមិនអនុលោមតាម សម្ព័ន្ធភាពពាណិជ្ជកម្ម នឹងមិនត្រូវបានបញ្ចប់ ដោយងាយៗឡើយប៉ុន្តែនឹងធ្វើ ការកែលម្អរួមគ្នា។

ច្បាប់ស្នូលរបស់យើងគឺ គ្រប់ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងក្រុមហ៊ុនចូលរួមទាំងអស់នៅក្នុង ខ្សែសង្វាក់ផ្គត់ផ្គង់ (អនុក្រុមហ៊ុន) ទាំងអស់ត្រូវតែធ្វើ តាមគោលការណ៍ ដែលមាននៅទីនេះនៅគ្រប់សកម្មភាព របស់ខ្លួនទាំងអស់។ បើសិនជាគោលការណ៍ណាមួយ របស់យើងពុំមានសុពលភាពដោយមូលហេតុ ច្បាប់ជាតិ របស់ប្រទេស ឬដែនដី នោះបទដ្ឋានខ្ពស់ជាតិនឹងត្រូវ បានអនុវត្តជានិច្ច។ ក្នុងករណីដូច្នេះ ដៃគូពាណិជ្ជកម្ម របស់ DEICHMANN ត្រូវតែជូនដំណឹងដល់ក្រុមហ៊ុន DEICHMANN ភ្លាមៗ។ ច្បាប់ ឬបទបញ្ញត្តិដែលមាន ស្រាប់លើសពីច្បាប់ក្នុងស្រុកដែល មានបទដ្ឋានខ្ពស់ ជាង នឹងមិនត្រូវលុបចោលឡើយ ពោលគឺត្រូវតែធ្វើ តាមជានិច្ច។



លោក Heinrich O. Deichmann ប្រធានក្រុមប្រឹក្សានាយក និងនាយកគ្រប់គ្រង

"ដៃគូពាណិជ្ជកម្មរបស់ DEICHMANN" គឺជាភាគីម៉ៅការដែលទទួលខុសត្រូវចំពោះផលិតផល ដំណើរការ ឬសេវា និងអាចធានាថាស្តង់ដារសង្គម ត្រូវបានបំពេញទៅតាមមុខតំណែងរបស់ខ្លួននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ និយមន័យនេះ អាចអនុវត្តចំពោះក្រុមហ៊ុនផលិតផល ក្រុមហ៊ុនចែកចាយ ក្រុមហ៊ុននាំចូល ក្រុមហ៊ុនដំឡើង ស្ថាប័នសេវា ។ល។

"អនុក្រុមហ៊ុន" គឺជាស្ថាប័នសេដ្ឋកិច្ចមួយនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដែលធ្វើការផ្គត់ផ្គង់ទំនិញ និង/ឬសេវាដោយផ្ទាល់ឬដោយប្រយោលដល់ក្រុមហ៊ុនផ្គត់ផ្គង់ ដែលត្រូវបានប្រើនៅក្នុង ឬសម្រាប់ផលិតកម្មទំនិញ ឬការផ្តល់សេវារបស់ក្រុមហ៊ុនផ្គត់ផ្គង់សំខាន់ៗ។

## 1. ការចូលរួម និងការការពារនិយោជិត

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុនផ្សេងៗនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែកំណត់ការអនុវត្តការគ្រប់គ្រងដែលអាចទុកចិត្តបាន ដើម្បីឲ្យមានការចូលរួមពីនិយោជិត និងអ្នកតំណាងរបស់ពួកគេនៅក្នុងការផ្លាស់ប្តូរព័ត៌មានស៊ីជម្រៅអំពីបញ្ហានៅកន្លែងធ្វើការ។ ពួកគេត្រូវតែអនុញ្ញាតឲ្យមានវិធានការសមស្របដើម្បីការពារនិយោជិត ដោយអនុលោមតាមកម្មវត្ថុនៃក្រមសីលធម៌ DEICHMANN ព្រមទាំងអនុញ្ញាតនូវជំហានសំខាន់ៗ ដើម្បីផ្តល់ការអប់រំដល់និយោជិតអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ពួកគេ។

លើសពីនេះ ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មានកាតព្វកិច្ចត្រូវកសាងសមត្ថភាពគ្រប់គ្រាន់ ដល់អ្នកគ្រប់គ្រងនិយោជិតនិងអ្នកតំណាងនិយោជិតដើម្បីបញ្ជ្រាបវិធានការទាំងនេះឲ្យបានជោគជ័យ នៅក្នុងប្រតិបត្តិការពាណិជ្ជកម្ម។ ការអប់រំ និងការបណ្តុះបណ្តាលបន្តបន្ទាប់នៅគ្រប់លំដាប់ថ្នាក់ គឺមានសារៈសំខាន់ណាស់ជាពិសេសទាក់ទងនឹងសុវត្ថិភាពការងារ។

នៅកម្រិតប្រតិបត្តិការដៃគូពាណិជ្ជកម្មរបស់DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែបង្កើត និង ចូលរួមនៅក្នុងយន្តការណ៍ដោះស្រាយការត្អូញត្អែរប្រកបដោយប្រសិទ្ធិភាព សម្រាប់បុគ្គល និងសហគមន៍ដែលអាចរងផល ប៉ះពាល់ ពីឥទ្ធិពលអវិជ្ជមាន។ ទោះបីជាតំបន់ដែល មានប្រព័ន្ធច្បាប់មានប្រសិទ្ធិភាព និងអនុវត្តល្អយន្តការដោះស្រាយការត្អូញត្អែរ អាចផ្តល់នូវអត្ថប្រយោជន៍ ពិសេសៗដូចជាការទាក់ទងបានរហ័សទៅកាន់មនុស្សដែលគួរឲ្យទុកចិត្តបាន ព្រមទាំងដំណោះស្រាយ រហ័សសម្រាប់កង្វះខាតផ្សេងៗដែលអាចបាន។

## 2. ពលកម្មកុមារ និងការការពារនិយោជិតវ័យក្មេង

កិច្ចការទាំងឡាយ ដែលត្រូវបានធ្វើដោយមនុស្សវ័យក្រោម 15 ឆ្នាំគឺត្រូវបានចាត់ទុកថាជាពលកម្មកុមារ លុះត្រាតែការចុះបញ្ជីក្នុងស្រុក ផ្តល់នូវអាយុអប្បបរមាខ្ពស់ជាងឬរយៈពេលការអប់រំជាកំហិតយូរជាង។ ក្នុងករណីនេះអាយុដែលខ្ពស់ជាងត្រូវបានអាទិភាព។ បើទោះបីជាអាយុអប្បបរមាតាមផ្លូវច្បាប់ អនុលោមតាមការលើកលែងដែលបានកំណត់នៅក្នុងអនុសញ្ញា ILO 138 សម្រាប់ប្រទេសកំពុងអភិវឌ្ឍគឺ 14 ឆ្នាំក៏ដោយ អាយុទាបជាងនេះគឺមានការពាក់ព័ន្ធ។

និយោជិតដែលមានវ័យចំណាស់ជាងកុមារដូចរៀបរាប់ខាងលើនិងមានវ័យក្រោម 18 ឆ្នាំគឺត្រូវបានចាត់ទុកថា "និយោជិតវ័យក្មេង"។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មិនគួរប្រើប្រាស់កម្លាំងពលកម្មកុមារដូចរៀបរាប់ខាងលើដោយផ្ទាល់ ឬដោយប្រយោល ឬបណ្តោយឲ្យមានឡើយ។ ពួកគេឯកភាពរៀបចំយន្តការ ដែលអាចទុកចិត្តបានសម្រាប់កំណត់អាយុនៅក្នុងបរិបទនៃដំណើរការជួល ដោយទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយ មិនត្រូវនាំឲ្យមានការប៉ះពាល់ ឬការផ្តល់អត្ថប្រយោជន៍ថមថយដល់បុគ្គលិកឡើយ។

ក្នុងករណីដែលកុមារ គឺជាជនរងគ្រោះនៃពលកម្មកុមារដូចរៀបរាប់ខាងលើ និងត្រូវបានដកខ្លួនរួច ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែបង្កើតវិធីសាស្ត្រ និងនីតិវិធីរក្សាឯកសារពីជនរងគ្រោះទាំងនោះ និងផ្តល់ជាព័ត៌មានដល់និយោជិតរបស់ខ្លួន និងភាគីដែលចាប់អារម្មណ៍ដែលធានាសន្តិសុខ សុខភាព ការអប់រំ និងការលូតលាស់របស់កុមារទាំងនេះ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ត្រូវតែអនុញ្ញាត កុមារទាំងនោះឲ្យចូលសាលារៀនតាមរយៈការឧបត្ថម្ភគ្រប់គ្រាន់រហូតដល់ពួកគេលែងជាកុមារ ដែលមានដូចរៀបរាប់ខាងលើ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែបង្កើតវិធីសាស្ត្រ និងនីតិវិធី រក្សាឯកសារពីជនរងគ្រោះទាំងនោះ និង ផ្តល់ជាព័ត៌មានដល់និយោជិតរបស់ខ្លួន និងភាគីដែលចាប់អារម្មណ៍ដែលលើកកម្ពស់ការអប់រំកុមារតាមអនុសាសន៍ ILO 146 ដែលត្រូវឆ្លងកាត់ច្បាប់ក្នុងស្រុកស្តីពីការអប់រំជាកំហិត ឬស្តីពីការចូលសាលា។ នេះរាប់បញ្ចូលវិធានការ ដែលធានាថាគ្មានកុមារ ឬ កម្មករវ័យជំទង់ណាម្នាក់ត្រូវបានជួលនៅក្នុងម៉ោងសិក្សា និងធានាថាពេលវេលាសរុប ដែលចំណាយសម្រាប់ការធ្វើដំណើរ (ធ្វើដំណើរពីកន្លែងធ្វើការទៅ និងមកពីសាលារៀន) ការអប់រំ និងការងារមិនលើសពី 10 ម៉ោងក្នុងមួយថ្ងៃ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ធានាថាកម្មករវ័យក្មេងមិនធ្វើការងារនៅពេលយប់ និងត្រូវបានការពារនៅក្រៅកន្លែងធ្វើការពីលក្ខខណ្ឌ ដែលគ្រោះថ្នាក់ដល់សុខភាពសុវត្ថិភាព ចរិយាធម៌ព្រមទាំងការអភិវឌ្ឍន៍ផ្លូវចិត្ត និងរាងកាយផងដែរ។ ក្រុមហ៊ុនផ្តល់ឲ្យកម្មករវ័យក្មេងនូវការប្រើយន្តការតវ៉ាប្រកបដោយប្រសិទ្ធិភាព ប្រព័ន្ធសាលារៀន និងកម្មវិធីស្តីពីសុខភាពនិងសុវត្ថិភាពការងារ។

## 3. ពលកម្មបង្ខិតបង្ខំ

កិច្ចការ ឬសេវាទាំងឡាយណាដែលត្រូវបានទាមទារពីបុគ្គល ដែលស្ថិតក្រោមការគំរាមកំហែងនៃការដាក់ពិន័យ និងសម្រាប់ការងារដែលបុគ្គលបំពេញការងារនោះមិនស្ម័គ្រចិត្តធ្វើ គឺត្រូវបានចាត់ទុកថាជាពលកម្មបង្ខិតបង្ខំ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មិនត្រូវប្រើប្រាស់កម្លាំងពលកម្មបង្ខិតបង្ខំ ឬកំហិតដោយមានដូចជាកាតព្វកិច្ចបំណុល, ទាសភាព, ការជួញដូរមនុស្ស, ឬពលកម្មអ្នកទោសឬបណ្តោយឲ្យមានឡើយ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ អាចប្រឈមនឹងការចោទប្រកាន់ពីការសមគំនិត បើសិនជាពួកគេទទួលបានផលប្រយោជន៍ពីការងារក្នុងរូបភាពនេះតាមរយៈដៃគូពាណិជ្ជកម្មរបស់ខ្លួននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។

កម្មករ មិនត្រូវបានតម្រូវដោយដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឲ្យបង់ប្រាក់ធានាខ្លួន ឬឯកសារផ្ទាល់ខ្លួននៅពេលជ្រើសរើសឡើយ។ និយោជិតមានសិទ្ធិឈប់ពីការងារគ្រប់ពេលវេលាដោយសេរី និងមានសិទ្ធិបញ្ចប់ទំនាក់ទំនងការងារ ដោយគោរពតាមរយៈពេលជូនដំណឹងសមស្របដល់និយោជក។

## 4. វិធានការវិន័យ

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ធានាថានិយោជិតមិនត្រូវបានទទួលរងនូវទង្វើឥតមនុស្សធម៌ ឬការផ្តល់អត្ថប្រយោជន៍ថមថយ, ការបំពារបំពានផ្លូវភេទ, ការធ្វើ ទណ្ឌកម្មផ្លូវកាយ, ការបង្ខិតបង្ខំផ្លូវចិត្ត ឬផ្លូវកាយ និង/ឬ ការធ្វើទុក្ខទោសដោយពាក្យសម្តីឡើយ។

វិធានការវិន័យសំខាន់ៗ គឺត្រូវសរសេរជាលាយលក្ខណ៍អក្សរជានិច្ច និងត្រូវពន្យល់ផ្ទាល់មាត់ឲ្យបានច្បាស់លាស់ និងអាចយល់បានសម្រាប់កម្មករ។

## 5. ការរើសអើង

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មិនត្រូវរើសអើសចំពោះជនណាម្នាក់ដោយសារជាតិសាសន៍, វណ្ណៈ, កំណើត, វណ្ណៈសង្គម, ដើមកំណើតជាតិសាសន៍ ឬសញ្ជាតិ, ពិការភាព, ទិសដៅផ្លូវភេទ, សមាជិកភាពក្នុងអង្គភាព, ទំនាក់ទំនងនយោបាយ, កាតព្វកិច្ចគ្រួសារ ឬភេទរបស់ពួកគេ ឬបណ្តាយឲ្យបានការរើសអើង  បែបនោះនៅក្នុងការជ្រើសរើសបុគ្គលិក, ការផ្តល់រង្វាន់, ការបណ្តុះបណ្តាល, ការដំឡើងតំណែង, ការបញ្ចប់ កិច្ចសន្យា ឬការចូលនិវត្តន៍ឡើយ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ នឹងមិនរារាំងនិយោជិតមិនឲ្យប្រើប្រាស់សិទ្ធិរបស់ពួកគេដើម្បីគោរពតាមលទ្ធិ ឬការអនុវត្តន៍ ឬដើម្បីអនុលោមតាមតម្រូវការ, ទាក់ទងនឹងជាតិសាសន៍, វណ្ណៈសង្គម, ដើមកំណើតជាតិសាសន៍, សាសនា, ពិការភាព, ភេទ, ទិសដៅផ្លូវភេទ, សមាជិកភាពក្នុងសមាគម ឬទំនាក់ទំនងនយោបាយឡើយ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មិនត្រូវអនុញ្ញាតអាកប្បកិរិយាដូចជាកាយវិការ, ការបង្ហាញជាពាក្យសម្ដី, ឬការប៉ះពាល់រូបកាយ ដែលបង្ហាញពីការបំពារបំពានផ្លូវភេទ ការគំរាមកំហែង ការរំលោភបំពាន ឬការកេងប្រវ័ញ្ចឡើយ។

យ៉ាងតិចបំផុត ការឈប់សម្រាកពេលសម្រាលកូនត្រូវតែផ្តល់ដល់និយោជិតមុន និងក្រោយសម្រាលកូន។ និយោជិត មិនត្រូវបានបញ្ឈប់ពីការងារដោយសារការមានផ្ទៃពោះឡើយ។ និយោជិតដែលមានផ្ទៃពោះ មិនត្រូវបានដាក់ឲ្យបម្រើការនៅទីកន្លែងដែលប៉ះពាល់ដល់សុខភាពរបស់ពួកគេឡើយ។

## 6. ការងារមិនជាក់លាក់

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ទទួលខុសត្រូវថាការរៀបចំការងាររបស់ខ្លួនមិនគ្រោះថ្នាក់ ឬមិននាំឲ្យមានការគំរាមកំហែងសង្គម ឬសេដ្ឋកិច្ចដល់និយោជិតឡើយ។ ពួកគេធ្វើឲ្យប្រាកដថាសកម្មភាពទាំងអស់ត្រូវបានធ្វើឡើងដោយឈរលើមូលដ្ឋាននៃការរៀបចំការងារដែលបានទទួលស្គាល់ និងមានឯកសារត្រឹមត្រូវដោយអនុលោមតាមច្បាប់ជាតិ ពន្ធគយឬការអនុវត្តន៍ និងបទដ្ឋានពលកម្មអន្តរជាតិ ដែលអាស្រ័យលើអ្វី ដែលផ្តល់នូវការការពារខ្ពស់ជាង។

មុនពេលចូលជាទំនាក់ទំនងការងារ ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែផ្តល់ឲ្យនិយោជិតនូវព័ត៌មានច្បាស់លាស់អំពីសិទ្ធិ ភារកិច្ច និងស្ថានភាពការងារ របស់ពួកគេ ដោយរាប់បញ្ចូលទាំងម៉ោងធ្វើការ ការផ្តល់រង្វាន់ ការអនុញ្ញាតឲ្យឈប់សម្រាក ការ ការពារការងារ ការការពារពេលសម្រាលកូននិងការបើកប្រាក់។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែផ្តល់លក្ខខណ្ឌការងារសមស្រប។ នេះក៏មានដូចជានិយោជិតគាំទ្រដែលដើរតួនាទីជាអាណាព្យាបាល ឬអ្នកថែទាំ ជាពិសេសសម្រាប់អ្នកធ្វើចំណាកស្រុក និងកម្មករតាមរដូវដែលកូនៗរបស់ពួកគេ បានបន្សល់ទុកឲ្យរស់នៅឯស្រុកកំណើតរបស់អ្នកធ្វើចំណាកស្រុក។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មិនត្រូវបានទំនាក់ ទំនងការងារក្នុងរូបភាពដែលមិនមែនជាគោល បំណងនៃលក្ខខណ្ឌដោយចេតនាឡើយ។ នេះមានរាប់បញ្ចូលតែមិនដាក់កម្រិតត្រឹម ដូចជា (ក) កម្មវិធីបណ្តុះបណ្តាលដែលមិនមានជំនាញបង្រៀន ឬការងារទៀងទាត់ជាគោលដៅ (ខ) ការងារតាមរដូវកាល ឬម្តងម្កាល បើសិនជាវាត្រូវបានប្រើ ដើម្បីធ្វើឲ្យការការពារនិយោជិតចុះ

ក្រោយ និង (គ) កិច្ចសន្យាត្រឹមកម្លាំងពលកម្ម។ បន្ថែមលើនេះ ការប្រើកិច្ចព្រមព្រៀងមៅការបន្តមិនត្រូវធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់និយោជិតឡើយ។

## 7. ការផ្តល់រង្វាន់សមស្រប

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែធានាថាប្រាក់ឈ្នួលដែលបង់សម្រាប់បទដ្ឋានការងារតាមសប្តាហ៍ ឆ្លើយតបនឹងការផ្តល់ទាបបំផុត ឬបើខ្ពស់ជាង បទដ្ឋាន ឧស្សាហកម្មដែលបានអនុញ្ញាតដោយផ្អែកលើការ ចរចាររួម ហើយ អត្ថប្រយោជន៍សង្គមអនុញ្ញាតដោយច្បាប់ ត្រូវបានគោរព។ ប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍ ដែលបានបើក ត្រូវតែគ្រប់គ្រាន់ទោះក្នុងករណីណាក៏ដោយ ដើម្បីឆ្លើយតបតាមតម្រូវការមូលដ្ឋានរបស់ បុគ្គលិក, ដើម្បីអនុញ្ញាតឲ្យនិយោជិតនិងក្រុមគ្រួសារ របស់គេទទួលបាន ជីវភាពសមស្រប និងដើម្បីធានាថាមានប្រាក់ចំណូលអាចប្រើបានដោយសេរីមួយចំនួន។

ដៃគូពាណិជ្ជកម្មរបស់DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ធានាថាសមាធាតុជាក់លាក់នៃប្រាក់ឈ្នួល ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ពិសេស ត្រូវបានពន្យល់យ៉ាង ច្បាស់និងទៀងទាត់ដល់កម្មករម្នាក់ៗ។ ការកាត់ថ្លៃ ឈ្នួល ត្រូវបានអនុញ្ញាតតែក្រោមលក្ខខណ្ឌដែល កំណត់ដោយច្បាប់ ឬកំណត់ ដោយមានកិច្ចព្រមព្រៀងជាសមូហភាព ប៉ុណ្ណោះ។ ការកាត់បន្ថយតាមវិន័យគឺមិនត្រូវបាន អនុញ្ញាតឡើយ។ ចំនួននៃការផ្តល់រង្វាន់ត្រូវឆ្លើយតប តាមជំនាញ និងកម្រិតការ អប់រំរបស់និយោជិត និង សំដៅតាមម៉ោងធ្វើការទៀងទាត់។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ធានាថាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ត្រូវបានបើកទាន់ពេលវេលា ទៀងទាត់ និងពេញលេញដោយអនុលោមតាមច្បាប់ដែលអាចអនុវត្តបានទាំងអស់ និងធានាថាការផ្តល់រង្វាន់ ត្រូវបានបើកក្នុងទម្រង់ផ្លូវច្បាប់ និងក្នុងរូបភាពដែលពេញចិត្ត សម្រាប់និយោជិត។ ការបើកប្រាក់ជាភាគនៅក្នុង អត្ថប្រយោជន៍មិនមែនប្រាក់កាស ត្រូវបានអនុញ្ញាតដោយអនុលោមតាមវិធានការរបស់ILO។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ធានាថាគ្មានការបើកប្រាក់ខែស្មើរដល់កម្មករ ឬបំព្លែលក្ខខណ្ឌបណ្តុះបណ្តាលកើតឡើង ដែលបង្អាក់កាតព្វកិច្ចរបស់ខ្លួហាចំពោះនិយោជិតដោយអនុលោមតាមច្បាប់ការងារដែលអាចអនុវត្តបាន និងនីតិបញ្ញត្តិសន្តិសុខសង្គម និងវិធានការដែលពាក់ព័ន្ធឡើយ។

## 8. ម៉ោងធ្វើការសមស្រប

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែគោរពតាមច្បាប់ដែលអាចអនុវត្ត និងបទដ្ឋានឧស្សាហកម្មស្តីពីម៉ោងធ្វើការ។ គ្មានករណីមួយ ដែលគេតម្រូវឲ្យនិយោជិតធ្វើការទៀងទាត់លើសពី 48ម៉ោងក្នុងមួយសប្តាហ៍ឡើយ។ ត្រូវផ្តល់ឲ្យយ៉ាងតិចមួយថ្ងៃ ក្នុងការធ្វើការមួយសប្តាហ៍។ ទោះជាយ៉ាងណា ក្រុមហ៊ុន DEICHMANN ទទួលស្គាល់នូវករណីលើកលែង ដែលកំណត់ដោយILO។ នីតិបញ្ញត្តិជាតិដែលអាចអនុវត្ត ,បទដ្ឋានឧស្សាហកម្មដែលអាចប្រៀបធៀប ឬកិច្ចព្រមព្រៀងជាសមូហភាពត្រូវបកប្រែក្នុងនៃលក្ខខណ្ឌ គ្រោងការណ៍អន្តរជាតិដែលកំណត់ដោយ ILO។

នៅក្នុងករណីលើកលែងដែលកំណត់ដោយ ILO ដែនកំណត់ខាងលើ សម្រាប់ចំនួនម៉ោងធ្វើការអាចមានលើស នៅក្នុងករណីនេះការធ្វើការលើសម៉ោងគឺផ្អែកលើការស្ម័គ្រចិត្ត។ បើសិនជាការធ្វើការលើសម៉ោង (ច្រើនជាងម៉ោងធ្វើការមូលដ្ឋានប្រចាំសប្តាហ៍) ត្រូវបានឯកភាពជាមួយនិយោជិតរបស់ ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ គេត្រូវធានាថាទាំងនេះត្រូវបានផ្តល់ជា

កម្រិតពិសេសដោយមិនតិចជាងមួយបូកនិងមួយភាគបួននៃអត្រាធម្មតាឡើយ។ ការធ្វើការលើសម៉ោង គួរតែជាករណីលើកលែង និងត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីសំណាក់កម្មករជានិច្ច។

## 9. សេរីភាពនៃសមាគម និងការចរចារជាសមូហភាព

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ គោរពសិទ្ធិរបស់និយោជិតទាំងអស់ក្នុងការបង្កើត និងចូលរួមក្នុងសមគមនិយោជិត ដោយសេរី ព្រមទាំងគោរពការចូលរួមក្នុងការចរចារ ជាសមហភាព។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែផ្តល់ឲ្យនិយោជិតនូវវិធីសមស្របសម្រាប់ឲ្យសមាគមឯករាជ្យ និងសេរីចូលរួមចរចារជាមួយនិយោជក ស្តីពីបញ្ហានៅកន្លែងការងារក្នុងករណីដែលសិទ្ធិសេរីភាពសមាគម និងការចរចារជាសមូហភាពត្រូវបានដាក់កម្រិតដោយច្បាប់។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មិនមានការរើសអើងដោយសារសមាជិភាពក្នុងសម្ព័ន្ធពាណិជ្ជកម្ម ចំពោះនិយោជិតឡើយ នឹងមិនរាំងការទាក់ទងរបស់តំណាងរបស់គេជាមួយនិយោជិតនៅកន្លែងការងារ ឬការទាក់ទងគ្នាទៅវិញទៅមកឡើយ។

## 10. សុខភាព និងសុវត្ថិភាព

ដោយសន្មត់ថាដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ យល់ដឹងច្បាស់ពីឧស្សាហកម្ម និងហានិភ័យជាក់លាក់ដែលអាចកើតឡើង គេត្រូវផ្តល់នូវបរិស្ថានរស់នៅ និងការងារប្រកបដោយសុវត្ថិភាព អនាម័យ និងមានសុខភាពល្អ។ គេត្រូវចាត់តាំងអ្នកតំណាងក្រុមប្រឹក្សាប្រតិបត្តិដែលទទួលបន្ទុកសុខភាព និងសុវត្ថិភាពរបស់បុគ្គលិកទាំងអស់ ព្រមទាំងការបំពេញតាមធាតុ សុខភាពនិងសុវត្ថិភាពរបស់គោលការណ៍នេះ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែធ្វើសកម្មភាពសមស្របដើម្បីបង្ការគ្រោះថ្នាក់ ដែលទាក់ទងនឹងការងារ ឬការខូចសុខភាព ដែលកើតឡើងក្នុងពេលធ្វើការគ្រោះថ្នាក់ដែលជាលទ្ធផល ឬទាក់ទងនឹងការងារដោយកាត់បន្ថយកត្តាគ្រោះថ្នាក់ នៅក្នុងបរិស្ថានការងារ។ បុគ្គលងាយរងគ្រោះ ដោយមិនដាក់កំណត់ត្រឹម មនដូចជាកម្មករវ័យក្មេង ម្តាយវ័យក្មេង និងស្ត្រីមានផ្ទៃពោះ ព្រមទាំងអ្នកដែលមានពិការភាពទទួលបាននូវការការពារពិសេស។

កិច្ចសហប្រតិបត្តិដ៏សកម្មរវាងថ្នាក់គ្រប់គ្រង និងនិយោជិត ឬអ្នកតំណាងរបស់ពួកគេ គឺជាការសំខាន់ដើម្បីអនុវត្តប្រព័ន្ធក្នុងការធានានូវបរិស្ថានការងារដែលសុវត្ថិភាព និងមានសុខភាពល្អ។ នេះអាចសម្រេចទៅបានតាមរយៈ ការបង្កើតគណៈកម្មការសុវត្ថិភាពការងារ។ ក្រុមហ៊ុនរបស់ពួកគេ ធានាថាមានប្រព័ន្ធសម្រាប់ការកំណត់ វាយតម្លៃ បង្ការ និងគ្រប់គ្រងហានិភ័យសក្តានុពលសម្រាប់សុខភាព និងសុវត្ថិភាពរបស់កម្មករ។ ពួកគេចាត់វិធានការដែលបានប្រសិទ្ធិភាពដើម្បីបង្ការគ្រោះថ្នាក់ដែលអាចកើតឡើង របួស និង ជំងឺរបស់កម្មករដែលទាក់ទងនឹងលំហូរការងារ ឬកើតឡើងក្នុងពេលបំពេញការងារ។ វិធានការទាំងនេះគួរតែកាត់បន្ថយគ្រោះថ្នាក់ ដែលទាក់ទងនឹងបរិស្ថានការងារ។ ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែធានាថានិយោជិត ទទួលបាននូវការបណ្តុះបណ្តាលស្តីពីសុខភាពនិងសុវត្ថិភាព និងធានាថាការបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងវិញសម្រាប់និយោជិតថ្មី និងតែងតាំងវិញទាំងអស់។
ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ នឹងខិតខំប្រឹងប្រែងក្នុងការ

លើកកម្ពស់ការការពារកម្មករពីគ្រោះថ្នាក់ ដូចជាតាមរយៈប្រព័ន្ធធានារ៉ាប់រងជាកំហិត។ គេចាត់វិធានការដែលសមស្របទាំងអស់នៅក្នុងដែនឥទ្ធិពលរបស់ខ្លួន ដើម្បីធានាស្ថេរភាព និងសុវត្ថិភាពសម្ភារៈ និងអាគារដែលពួកគេប្រើប្រាស់ រួមទាំងសំណង់ស្នាក់នៅសម្រាប់និយោជិត បើសិនជាការស្នាក់នៅទាំងនេះត្រូវបានរៀបចំដោយនិយោជក ព្រមទាំងដើម្បីធានាឲ្យមានសុវត្ថិភាពក្នុងករណីអាសន្ននាពេលអនាគត។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ គោរពសិទ្ធិបុគ្គលិកក្នុងការឈប់សម្រាកពីការងារ ដើម្បីដកខ្លួនចេញពីគ្រោះថ្នាក់ភ្លាមៗ ដោយមិនចាំបាច់សុំការអនុញ្ញាតពីក្រុមហ៊ុន ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ធានានូវការថែទាំសុខភាពការងារសមស្របនិងសម្ភារៈដែលទាក់ទង។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ផ្តល់នូវការទទួលបានទឹកបរិភោគស្អាត កន្លែងបរិភោគអាហារ និងសម្រាកស្អាត និងមានសុវត្ថិភាព ព្រមទាំងផ្តល់នូវកន្លែងដែលស្អាត និងមានសុវត្ថិភាពសម្រាប់ការរៀបចំ និងស្តុកទុកចំណីអាហារ។ បន្ថែមលើនេះ គេផ្តល់នូវបរិក្ខារការងារផ្ទាល់ខ្លួន (PPE) ដែលមានប្រសិទ្ធិភាពដល់និយោជិតទាំងអស់នៅគ្រប់ពេលវេលាដោយឥតគិតថ្លៃ។ ដៃគូពាណិជ្ជកម្មរបស់ **DEICHMANN** និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែធានាថា ទីកន្លែងសម្រាក បន្ទប់ទឹក សម្ភារៈបោកគក់ស្អាតមានសុវត្ថិភាព និងឆ្លើយតបតាមតម្រូវការមូលដ្ឋាន បើសិនជាទាំងនោះមានសម្រាប់កម្មករប្រើប្រាស់។

## 11. ការការពារបរិស្ថាន

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែពិនិត្យប្រតិបត្តិការអំពីឥទ្ធិពលលើបរិស្ថានសំខាន់ៗ និងកំណត់គោលនយោបាយ និងនីតិវិធីប្រកបដោយប្រសិទ្ធិភាព ដែលឆ្លុះបញ្ចាំងពីទំនួលខុសត្រូវរបស់ខ្លួនចំពោះបរិស្ថាន និងធានាថាធនធានធម្មជាតិ ត្រូវបានប្រើឲ្យមានប្រសិទ្ធិភាពបំផុតតាមដែលអាចធ្វើបាន។ គេត្រូវគោរពតាម ច្បាប់ និងបទបញ្ញត្តិដែលអាចប្រើបាន ទាក់ទងនឹងការការពារបរិស្ថានរបស់ប្រទេស ដែលក្រុមហ៊ុនកំពុងធ្វើប្រតិបត្តិការ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ នឹងធានាការអនុវត្តន៍វិធានការសមស្រប ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើសហគមន៍ ធនធានធម្មជាតិ និងបរិស្ថានជារួម។ បើមានសារធាតុគ្រោះថ្នាក់គួរត្រូវបានចៀសវាង ឬប្រើក្នុងកម្រិតកំណត់។ សារធាតុទាំង នោះអាចត្រូវបានប្រើ លុះត្រាតែប្រើបានត្រឹមត្រូវ ហើយបរិស្ថានមិនរងផលប៉ះពាល់ពីការប្រើនោះ។

គេត្រូវតែធានា និងបញ្ជាក់ការចោលកាកសំណល់ និងឧបករណ៍ផ្ទុកត្រឹមត្រូវតាមបរិស្ថានតាមសំណើ។ កាកសំណល់ទាំងស្រុង ដែលបានមកពីផលិតកម្មត្រូវតែចោលឲ្យបានត្រឹមត្រូវ។

## 12. សេដ្ឋកិច្ចក្រមសីលធម៌

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ប្តេជ្ញាថាមិនចូលរួមក្នុងអំពើពុករលួយ, ការជំរិត ឬការកេងប្រវ័ញ្ច ឬការស៊ីសំណូកសូកប៉ាន់គ្រប់រូបភាព ដូចជាការសន្យា ការផ្តល់នូវគ្រឿងលើកទឹកចិត្តហិរញ្ញវត្ថុមិនយុត្តិធម៌ជាដើម។

ពួកគេត្រូវបានរំពឹងថា មានព័ត៌មានត្រឹមត្រូវអំពីសកម្មភាពរចនាសម្ព័ន្ធ និងការបំពេញការងាររបស់ខ្លួន និងថាពួកគេបង្ហាញព័ត៌មានទាំងនេះ ដោយអនុលោមតាមច្បាប់ដែលអាចអនុវត្ត និងការអនុវត្តឧស្សាហកម្មដែលអាចប្រៀបធៀបបាន។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុន នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ មិនចូលរួមក្នុងការក្លែងព័ត៌មាន នេះ ឬសកម្មភាពឆបោកក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឡើយ។ បន្ថែមលើនេះ គេត្រូវប្រមូល ប្រើ និងការពារព័ត៌មាន ផ្ទាល់ខ្លួន (ដូចជាព័ត៌មានពីកម្មករ ដៃគូ ពាណិជ្ជកម្ម និងអតិថិជននៅក្នុងដែនឥទ្ធិពលរបស់ខ្លួន) ជាមួយការ យកចិត្តទុកដាក់សមស្រប។ ការប្រមូល ប្រើប្រាស់ និងការពារទិន្នន័យផ្ទាល់ខ្លួននេះ ត្រូវតែធ្វើឡើងដោយ អនុលោមតាមនីតិបញ្ញត្តិ នឹងតម្រូវការ ផ្លូវច្បាប់ទាក់ទង នឹងការការពារទិន្នន័យនិងសុវត្ថិភាពព័ត៌មាន។

## 13. ប្រព័ន្ធគ្រប់គ្រង

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុន នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវចាត់វិធានការច្បាស់លាស់ ដើម្បីឆ្លើយតបតាម តម្រូវការរបស់ក្រមសីលធម៌ DEICHMANN ដើម្បីបញ្ចូលក្រមសីលធម៌នេះទៅគ្រប់ ដំណើរការពាណិជ្ជកម្មរបស់ខ្លួនទាំងអស់ និងដើម្បីធ្វើ ឲ្យវាក្លាយជាផ្នែកដ៏សំខាន់មួយនៃទស្សនៈវិជ្ជា និង គោលការណ៍ក្រុមហ៊ុនរបស់ខ្លួន។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុន នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែកំណត់ទំនួលខុសត្រូវ ដល់អ្នកគ្រប់គ្រង សម្រាប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធ នឹងក្រមសីលធម៌ DEICHMANN នៅក្នុងអង្គភាព របស់ខ្លួន។

ការគ្រប់គ្រងនៃដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែមាន ការត្រួតពិនិត្យម្តងម្កាលទៅលើ ការអនុវត្តន៍នៃតម្រូវការ ក្រមសីលធម៌DEICHMANN។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុន នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ទទួលខុសត្រូវលើការបំពេញ តាមតម្រូវការនៃក្រមសីលធម៌ DEICHMANN ទាក់ ទងនឹងនិយោជិតទាំងអស់ ដែលពួកគេគ្រប់គ្រង និង ឯកភាពថា

– ផ្ទេរទំនួលខុសត្រូវសម្រាប់ការអនុវត្តក្រមសីលធម៌ DEICHMANN ដល់នរណាម្នាក់នៅកន្លែងនីមួយៗ ដែលពួកគេកាន់កាប់ឬដឹកនាំ

– ធានាថានិយោជិតទាំងអស់ដឹងពី ក្រមសីលធម៌ DEICHMANN ដោយផ្តល់ខ្លឹមសារជាភាសាដែល អាចយល់បានដល់កម្មករ និងធ្វើការបណ្តុះបណ្តាល ទៀងទាត់អំពីក្រមសីលធម៌DEICHMANN

– ចៀសវាងពីវិធានការវិន័យ ការបណ្តេញចេញ ឬការ រើសអើងផ្សេងទៀតចំពោះកម្មករបែបនោះ ដែល ផ្តល់ព័ត៌មានអំពីការគោរពតាមក្រមសីលធម៌ DEICHMANN។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុន នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែធ្វើការបង្ហាញតាម រយៈរបាយការណ៍សមស្របដែលពួកគេអនុលោមតាម តម្រូវការរបស់ក្រមសីលធម៌ DEICHMANN។ ពួកគេ ត្រូវតែអាចផ្តល់របាយការណ៍ និងផ្តល់ព័ត៌មានគ្រប់ គ្រាន់ដល់ភាគីខាងក្រុមហ៊ុន DEICHMANN ដែលចង់ ផ្ទៀងផ្ទាត់ការបំពេញតាមតម្រូវការ។

ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុន នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវតែកំណត់ការអនុលោម តាមក្រមសីលធម៌ DEICHMANN ជាលក្ខខណ្ឌមួយ នៅក្នុងកិច្ចព្រមព្រៀងទាំងអស់ ដែលប្រើជាមួយអ្នក មៅការបន្ត។ កិច្ចព្រមព្រៀងទាំងនេះត្រូវតែប្តេជ្ញាឲ្យអ្នក មៅការបន្តអនុលោមតាមតម្រូវការទាំងអស់របស់ក្រម សីលធម៌ DEICHMANN (រួមទាំងវិធានការនេះ) និងឲ្យ ចូលរួមក្នុងសកម្មភាពត្រួតពិនិត្យរបស់អ្នកផ្គត់ផ្គង់តាម សំណើ។

## 14. ការសាកល្បង និងការត្រួតពិនិត្យ

ដើម្បីវាយតម្លៃ ការអនុលោមតាមក្រមសីលធម៌ DEICHMANN ក្រុមហ៊ុន DEICHMANN នឹងប្រើ ប្រាស់សវនករឯករាជ្យ ដែលធ្វើការវាយតម្លៃសង្គម

និងបរិស្ថានក្នុងនាមក្រុមហ៊ុន DEICHMANN។ ដោយ អាស្រ័យលើតួនាទីក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ លក្ខខណ្ឌ ការអនុវត្តន៍ផ្សេងៗអនុវត្ត សម្រាប់ដៃគូពាណិជ្ជកម្ម របស់'DEICHMANN។

យើងជា ក្រុមហ៊ុន DEICHMANN មានសិទ្ធិក្នុងការ ត្រួត ពិនិត្យការអនុលោម តាមក្រមសីលធម៌នេះ ជាលក្ខណៈ ប្រព័ន្ធ និងមិនផ្តល់ដំណឹងជាមុន។ ការធ្វើ អធិការកិច្ច ត្រូវបានធ្វើឡើងដោយសមាជិករបស់ ក្រុមហ៊ុន DEICHMANN ឬសវនករឯករាជ្យដោយ អនុលោមតាមគោលការណ៍ណែនាំនៃគំនិតផ្តួចផ្តើម ការអនុលោម សង្គមក្នុងមុខពាណិជ្ជកម្ម(BSCI)។

## 15. វិធានការកែតម្រូវ និងការមិនគោរពតាម

ក្រមសីលធម៌ DEICHMANN កំណត់គោលការណ៍ ដែលយើង រំពឹងការអនុលោមតាមពីសំណាក់ដៃគូ ពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុននៅ ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។

យើងដឹងថាការរំពឹងទុកមួយចំនួន មិនអាចត្រូវបាន អនុវត្តខ្ជាប់ខ្ជួន និងភ្លាមៗនៅគ្រប់ទីកន្លែងឡើយ។ វា ជាការសំខាន់សម្រាប់ក្រុមហ៊ុន DEICHMANN ដែល ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និងអនុក្រុមហ៊ុន នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ធ្វើសកម្មភាពកែ តម្រូវដើម្បី កែលម្អស្ថានភាព និងឆ្លើយតបតាមគោលការណ៍ទាំង នេះក្នុងពេលវេលាសមស្រប នៅពេលមានការមិន បំពេញតាម។ ការពន្យាពេលនេះ អាស្រ័យលើប្រភេទ នៃវិធានការដែលត្រូវកែតម្រូវ និងកម្រិតគ្រោះថ្នាក់ និង ត្រូវតែសម្របសម្រួលជាមួយក្រុមហ៊ុនDEICHMANN។

បើសិនជាមាន ការរំលោភបំពានម្តងហើយម្តងទៀត ដោយពុំមានការធ្វើសកម្មភាព កែតម្រូវសមស្របពី សំណាក់ដៃគូពាណិជ្ជកម្មរបស់ DEICHMANN និង អនុក្រុមហ៊ុននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់នោះទេ យើង មានកាតព្វកិច្ចក្នុងការបញ្ចប់ការសហប្រតិបត្តិការ។